# ជំពូកទី ៦

## ប្រកាច់ (Fits)
## ជំងឺឆ្កួតជ្រូក (Epilepsy)



**តើការប្រកាច់ជាអ្វី?** ការប្រកាច់(ដែលអ្នកខ្លះហៅថា ស្កន់ ឬការញាក់) គឺជាការបាត់បង់ស្មារតី ឬការផ្លាស់ប្តូរសភាពផ្លូវចិត្តដែលកើតឡើងភ្លាមៗ និងមានរយៈពេលខ្លី ហើយជារឿយៗមានចលនាកន្ត្រាក់ខុសពីប្រក្រតី។

ក្នុងចំណោមក្មេង១០ ឬ ២០នាក់ មានយ៉ាងតិចម្នាក់ដែលមានជំងឺប្រកាច់នៅអាយុប្រហែល ១៥ឆ្នាំ។ ប៉ុន្តែមានតែ ១ ក្នុង ចំណោម ៥០នាក់ ដែលឈានទៅដល់ការប្រកាច់រ៉ាំរ៉ៃ (ការប្រកាច់ម្តងហើយម្តងទៀតរយៈពេលយូរ) - ស្ថានភាពបែបនេះត្រូវបានគេស្គាល់ថាជា **ជំងឺឆ្កួតជ្រូក**។

## បុព្វហេតុនៃការប្រកាច់រ៉ាំរ៉ៃ(ជំងឺឆ្កួតជ្រូក)

ការប្រកាច់បណ្តាលមកពីការខូច ឬភាពមិនប្រក្រតីនៃខួរក្បាល។ បុព្វហេតុជាទូទៅរួមមាន :

- **របួសខួរក្បាល។** នេះជាបុព្វហេតុចំនួន ១/៣ នៃជំងឺឆ្កួតជ្រូក។ របួសនេះអាចកើតឡើងមុនពេលកើត ពេលកំពុងកើត ឬខណៈណាមួយក្រោយពេលកើត។ បុព្វហេតុនៃការខូចខួរក្បាលដូចគ្នានេះ ដែលបណ្តាលអោយកើតជំងឺប្រគ្រីវ ក៏អាចបណ្តាលអោយកើតជំងឺឆ្កួតជ្រូកដែរ(សូមអានទំព័រ ២៣)។ ជាក់ស្តែង**ជំងឺប្រគ្រីវ និងឆ្កួតជ្រូក ច្រើនកើតជាមួយគ្នា**។ **រោគរលាកស្រោមខួរ** ជាបុព្វហេតុចំបងនៃការកើតព្រមគ្នានេះ។ ចំពោះក្មេងតូចៗបុព្វហេតុចំបងនៃការប្រកាច់គឺ **គ្រុនក្តៅខ្លាំង** ឬ**ការខ្វះជាតិទឹកច្រើន**។ ចំពោះអ្នកជំងឺបុព្វហេតុចំបងអាចជា **រោគរលាកស្រោមខួរ គ្រុនចាញ់នៃខួរក្បាល** ឬ**ការពុល**(សូមអាន*នៅកន្លែងដែលគ្មានគ្រូពេទ្យ*)។ ជំងឺឆ្កួតជ្រូកដែលមានសភាពធ្ងន់ធ្ងរទៅៗ ជាពិសេសប្រសិនបើមានសញ្ញានៃការខូចខួរក្បាលលេចឡើង អាចជាសញ្ញានៃ**ការដុះសាច់ខួរក្បាល** (ឬ**ទឹកចូលក្នុងខួរក្បាល** ចំពោះទារក — សូមអានទំព័រ ៥១)។ ការប្រកាច់ដែលបណ្តាលមកពីការដុះសាច់ខួរក្បាល អាចប៉ះពាល់ផ្នែកម្ខាងនៃរាងកាយច្រើនជាងផ្នែកម្ខាងទៀត។ ការប្រកាច់អាចបណ្តាលមកពីតេនញ៉ាជ្រូក ដែលកជាដុំពកក្នុងខួរក្បាលតែវាជាករណីកម្រ។
- **ស្នូរពូជ**។ ១/៣ ក្នុងចំណោមអ្នកកើតជំងឺប្រកាច់ ធ្លាប់មានសមាជិកក្នុងគ្រួសារកើតជំងឺនេះដែរ។
- **មិនដឹងបុព្វហេតុ**។ ក្នុងចំណោម ១/៣ នៃជំងឺឆ្កួតជ្រូក មិនមានប្រវត្តិគ្រួសារ ឬការខូចខួរក្បាលនោះទេ។

**ការប្រកាច់ដោយគ្រុនក្តៅ**។ ក្មេងដែលធ្លាប់ប្រកាច់ដោយសារគ្រុនក្តៅខ្លាំង ជារឿយៗនឹងប្រកាច់ទៀតនៅពេលដែលពួកគេគ្រុនក្តៅ — ជាពិសេសប្រសិនបើសមាជិកក្នុងគ្រួសារធ្លាប់ប្រកាច់ពេលគ្រុនក្តៅ។ ត្រូវពិនិត្យរកមើល**ជំងឺឆ្លង**ក្នុងត្រចៀក និងបំពង់កក៏ដូចជាបាក់តេរីនៃរោគរាគមូល (រាគមានទឹកលាយឈាម) និង**ព្យាបាលបុព្វហេតុនោះ**។

ការប្រកាច់តែនៅពេលគ្រុនក្តៅ ជាធម្មតានឹងឈប់កើតមាននៅពេលដែលក្មេងអាយុ ៧ឆ្នាំ។ ជួនកាលពួកគេអាចឈានទៅរក"ជំងឺឆ្កួតជ្រូកដែលមិនពាក់ព័ន្ធនឹងគ្រុនក្តៅ" ជាពិសេសប្រសិនបើក្មេងមានសញ្ញានៃការខូចខួរក្បាល(សូមអាន"ជំងឺប្រគ្រីវ"ទំព័រ ១៩ និង ២០)។

***ចំណាំ*** : ការប្រកាច់នៃក្មេងគ្រប់រូប អាចជាសញ្ញានៃ**រោគរលាកស្រោមខួរ** —ដែលត្រូវការការព្យាបាលជាបន្ទាន់ដើម្បីសង្គ្រោះជីវិតរបស់វា។ ចូររៀនរបៀបពិនិត្យរកមើលសញ្ញានៃ រោគរលាកស្រោមខួរ(សូមអាន*នៅកន្លែងដែលគ្មានគ្រូពេទ្យ*)។



ការតាំងរឹងដោយសារ**ជំងឺតេតាណុស** អាចច្រលំគ្នានឹងការប្រកាច់។ ថ្គាមបិទយ៉ាងណែន(រឹងថ្គាម) ហើយរាងកាយពត់ទៅក្រោយភ្លាមៗ។ ចូររៀនពិនិត្យរកមើលសញ្ញាដំបូងនៃជំងឺតេតាណុស។



## ចំណុចបន្ថែមស្តីពីការប្រកាច់ (ជំងឺឆ្កួតជ្រូក)

**សមត្ថភាពផ្លូវចិត្ត។** ក្មេងខ្លះដែលមានជំងឺឆ្កួតជ្រូកមានប្រាជ្ញាវៃឆ្លាត។ ក្មេងផ្សេងទៀតមានសភាពផ្លូវចិត្តយឺត។ យូរៗម្តងការប្រកាច់កើតឡើងញឹកញាប់ ហើយខ្លាំងអាចធ្វើរបួសខួរក្បាល និងបង្ក ឬបង្កើន***ភាពយឺតយ៉ាវនៃការលូតលាស់ប្រាជ្ញា***។ ការព្យាបាលដើម្បីគ្រប់គ្រងការប្រកាច់នេះមានសារៈសំខាន់។

**ប្រភេទនៃការប្រកាច់។** ការប្រកាច់កើតឡើងខុសៗគ្នាចំពោះក្មេងផ្សេងៗគ្នា។ ក្មេងខ្លះអាចប្រកាច់ខ្លាំង មិនអាចគ្រប់គ្រងចលនាបាន ថែមទាំងបាត់បង់ស្មារតី។ ក្មេងដទៃទៀតអាចប្រកាច់បន្តិចបន្តួច។ វាអាចកើតឡើងរយៈពេលយ៉ាងខ្លី ដោយមានការធ្វើចលនាមិនប្រក្រតីនៃផ្នែកខ្លះនៃរាងកាយ។ វាអាចជាឥរិយាបថមិនប្រក្រតីមួយចំនួនដែលកើតឡើងភ្លាមៗ ដូចជាការជញ្ជក់បបូរមាត់ ឬការទាញសំលៀកបំពាក់។ ឬវាអាចជាការភ្លឹកមួយសន្ទុះដែលភ្លាមៗនោះក្មេងឈប់ ហើយសម្លឹង — ប្រហែលមានការព្រិចភ្នែក ឬត្របកភ្នែកធ្វើចលនាលឿន។

ក្មេងខ្លះអាចប្រកាច់បន្តិចបន្តួចផង និងប្រកាច់ខ្លាំងផង ឬពួកវាដំបូងប្រកាច់បន្តិចបន្តួច ក្រោយមកក៏ប្រកាច់ខ្លាំង។

**អាការៈ ឬសញ្ញាអាសន្ន។** អាស្រ័យទៅលើប្រភេទនៃការប្រកាច់ ក្មេង(និងឪពុកម្តាយ) អាចមានអារម្មណ៍ដឹងនៅពេលដែលជិតនឹងប្រកាច់។ ក្មេងខ្លះធ្លាប់ទទួល"សញ្ញាអាសន្ន" ដោយមើលឃើញពន្លឺ ឬពណ៌ភ្លឺបភ្លែតៗ។ ឬភ្លាមៗវាស្រែកយំ។ ការប្រកាច់មួយប្រភេទនោះ សញ្ញាអាសន្នគឺជាការភ័យខ្លាច ឬរូបភាព សំលេង ក្លិន ឬរស់ជាតិស្រមើលស្រមៃ។ ការប្រកាច់ខ្លះ មិនមានសញ្ញាអាសន្ននោះទេ។ រាងកាយរបស់ក្មេងកន្ត្រាក់ ឬគ្រវាត់គ្រវែងភ្លាមៗតែម្តង។ ក្មេងទាំងនេះអាចត្រូវការពាក់មួកសុវត្ថិភាព ឬប្រដាប់ការពារក្បាលជាប្រចាំ។

**ពេលវេលានៃការប្រកាច់។** ការប្រកាច់អាចកើតឡើងក្នុងចន្លោះពេលជាច្រើនសប្តាហ៍ ឬច្រើនខែ ឬញឹកញាប់តែម្តង។ ការប្រកាច់បន្តិចបន្តួច ឬការភ្លឹកអាចកើតឡើងជាក្រុម — ជារឿយៗនៅពេលព្រឹកព្រលឹម ឬពេលរសៀល។

ការប្រកាច់ជាធម្មតាកើតឡើងក្នុងរយៈពេលមួយខ្លី។ ការប្រកាច់បន្តិចបន្តួចអាចកើតឡើងតែរយៈពេល ២ ឬ ៣ វិនាទីប៉ុណ្ណោះ។ ការប្រកាច់ខ្លាំងកម្រនឹងកើតឡើងយូរជាង ១០ ឬ ១៥ នាទី ណាស់។ ប៉ុន្តែយូរៗម្តងក្មេងអាចស្ថិតក្នុងស្ថានភាពឆ្កួតជ្រូករយៈពេលយូរអាចដល់ទៅរាប់ម៉ោង។ សភាពបែបនេះត្រូវការការសង្គ្រោះផ្នែកវេជ្ជសាស្ត្រ។

ការប្រកាច់ប្រភេទខ្លះ អាចកើតឡើងនៅគ្រប់អាយុរបស់ក្មេង។ ឯប្រភេទខ្លះទៀតកើតឡើងនៅពេលកុមារភាព ហើយជាធម្មតាបាត់ទៅវិញ ឬប្តូរទៅជាប្រភេទផ្សេងទៀតនៅពេលដែលក្មេងកាន់តែចំរើនវ័យ។

មនុស្សជាច្រើនកើតជំងឺឆ្កួតជ្រូកពេញមួយជីវិតរបស់គេ។ ប៉ុន្តែក្មេងខ្លះវិលងកើតជំងឺឆ្កួតជ្រូកបន្ទាប់ពីរយៈពេលពីរ បីខែ ឬឆ្នាំ។

ជាធម្មតាមិនចាំបាច់ស្គាល់ប្រភេទនៃការប្រកាច់ ដែលកើតចំពោះក្មេងនោះទេ។ ប៉ុន្តែការប្រកាច់ប្រភេទខ្លះតូវការឱសថផ្សេងៗគ្នា។ **តារាងនៅទំព័រ ៦៤ និង ៦៥** ពិពណ៌នាប្រភេទនៃការប្រកាច់ផ្សេងៗគ្នា ពេលវេលាដែលវាចាប់ផ្តើម និងការព្យាបាល។

## តើពេលណាត្រូវការការសិក្សាផ្នែកវេជ្ជសាស្ត្រជាពិសេស?

នៅប្រទេសក្រីក្រមួយចំនួន វេជ្ជបណ្ឌិតចេញវេជ្ជបញ្ជា សំរាប់ការប្រកាច់ដោយពុំបានពិនិត្យអោយបានសព្វជ្រុងជ្រោយ រកសញ្ញានៃបុព្វហេតុដែលត្រូវការការយកចិត្តទុកដាក់។ ប៉ុន្តែច្រើនឡើងៗ វេជ្ជបណ្ឌិតបានបង្គាប់ការពិនិត្យថ្លៃៗជាទៀងទាត់ ដូចជាអគ្គិសនីខួរក្បាលលេខ(EEG)។ ថ្វីបើសេវានេះមិនបង់ថ្លៃក៏ដោយ វាមិនមាននៅកន្លែងដែលដាច់ស្រយាលនោះទេ ដែលបណ្តាលអោយក្រុមគ្រួសារត្រូវចំណាយពេលវេលា និងប្រាក់អស់ច្រើន។ ការពិនិត្យនេះមិនអាចជួយបានច្រើនប៉ុន្មានទេ ក្នុងការកំណត់ការព្យាបាល —ប្រសិនបើគ្មានការសង្ស័យដល់ការដុះសាច់ក្នុងខួរក្បាលនោះទេ។ ហើយប្រសិនបើវាជាការដុះសាច់ក្នុងខួរក្បាលមែននោះឱកាសនៃការវះកាត់ ឬការព្យាបាលដោយជោគជ័យមានតិចណាស់ ហើយចំណាយខ្ពស់ខ្លាំងណាស់។

**ជាធម្មតា EEG និងការពិនិត្យដែលមានតំលៃថ្លៃផ្សេងទៀត មិនមានប្រយោជន៍ប៉ុន្មាននោះទេ។**

# តើត្រូវធ្វើដូចម្តេចបើក្មេងមានជំងឺប្រកាច់

- រៀនសំគាល់"សញ្ញាអាសន្ន"ដែលជួយអោយដឹងថា ក្មេងបំរុងនឹងប្រកាច់ ដូចជាការភ័យខ្លាច ឬការយំ ។ ការពារក្មេងអោយបានលឿន ដោយដាក់អោយវាដេកលើកំរាលទន់ៗ ឬកន្លែងផ្សេងទៀតដែលវាមិនអាចបង្កគ្រោះថ្នាក់ដល់ខ្លួនវាបាន ។
- នៅពេលដែលកំពុងប្រកាច"ខ្លាំង" ចូរកុំព្យាយាមផ្លាស់ទីក្មេង លើកលែងតែវាស្ថិតនៅកន្លែងគ្រោះថ្នាក់ ។
- **ការពារក្មេងអោយអស់ពីលទ្ធភាពពីគ្រោះថ្នាក់នានា ប៉ុន្តែមិនត្រូវព្យាយាមគ្រប់គ្រងចលនារបស់វា ដោយកំលាំងនោះទេ ។** យកវត្ថុដែលមុត ឬរឹងនៅជិតខ្លួនវាចេញអោយឆ្ងាយ ។
- **កុំដាក់អ្វីចូលមាត់ក្មេងពេលដែលវាកំពុងប្រកាច់** - កុំដាក់ចំណីអាហារ ទឹក ថ្នាំ ឬវត្ថុអ្វីមួយដើម្បីការពារការខាំអណ្តាត ។
- នៅចន្លោះពេលនៃការរឹងគាំង ចូរបត់ក្បាលរបស់ក្មេងទៅចំហៀង ដើម្បីអោយទឹកមាត់ហៀរចេញមកក្រៅ ហើយវាមិនដកដង្ហើមយកចូលទៅក្នុងសួតរបស់វា ។
- បន្ទាប់ពីប្រកាច់រួចក្មេងអាចងងុយដេក និងច្របូកច្របល់ ។ **ចូរអោយវាដេកចុះ** ។ ចំពោះ**ការឈឺក្បាល**ដែលជាបញ្ហាធម្មតាបន្ទាប់ពីការប្រកាច់ ចូរផ្តល់ថ្នាំបំបាត់ការឈឺចាប់ដូចជា ប៉ារាសេតាម៉ុល ឬអាស្ពីរីន ។

### ការការពារក្បាល

ដើម្បីការពារក្បាលក្មេងដែលដួលខ្លាំងពេលវាប្រកាច់ វាគួរតែពាក់ប្រដាប់ការពារក្បាលសឹងតែគ្រប់ពេលវេលា ។




ក្មេងដែលរងរបួសមុខជារឿយៗ ដោយសារការប្រកាច់ អាចត្រូវការមួកការពារដែលរឹង និងមានរបាំងការពារមុខ ។



អ្នកអាចធ្វើ"ទ្រុង"ពីសរសៃលួសរឹង ហើយរុំវានឹងបន្ទះក្រណាត់ ផ្នែកខាងក្នុងនៃទុយូ ក្រណាត់ទន់ៗ ឬបន្ទះកៅស៊ូស្តោត ។



ឬកាត់បន្ទះកៅស៊ូឡានចាស់ៗដូចនេះ ។



ឬបន្ទះក្រណាត់ដែលមានញាត់ទ្រនាប់ពីក្នុង ។



## ឱសថសំរាប់បង្ការការប្រកាច់

គ្មានថ្នាំសំរាប់ព្យាបាលជំងឺឆ្កួតជ្រូកនោះទេ ។ ប៉ុន្តែមានថ្នាំសំរាប់បង្ការការប្រកាច់នៃក្មេងភាគច្រើនបាន —ដរាបណាពួកវាបន្តលេបជាទៀងទាត់ ។ **ដរាបណាក្មេងនៅតែកើតជំងឺឆ្កួតជ្រូក —ដែលអាចមានរយៈពេលរាប់ឆ្នាំ ឬអស់មួយជីវិត —វាត្រូវតែបន្តប្រើថ្នាំប្រឆាំងនិងការប្រកាច់ ។**

ពេលខ្លះការបង្ការការប្រកាច់យូរទៅ ហាក់ដូចជាអាចជួយបញ្ឈប់ជំងឺឆ្កួតជ្រូកជាអចិន្ត្រៃយ ។ ដោយសារហេតុផលនេះ ប្រសិនបើ ក្មេងមានជំងឺប្រកាច់ច្រើនពីអតីតកាល វាគួរតែបន្តលេបថ្នាំប្រឆាំងការប្រកាច់រយៈពេលយ៉ាងតិច១ឆ្នាំ បន្ទាប់ពីការប្រកាច់ចុងក្រោយ ។ បន្ទាប់ពីរយៈពេលនោះមកអ្នកគួរបន្ថយការប្រើប្រាស់ថ្នាំបន្តិចម្តងៗ ហើយបញ្ឈប់ការព្យាបាលដើម្បីពិនិត្យមើលថា វានៅត្រូវការថ្នាំនោះទៀតឬទេ ។

***ប្រុងប្រយ័ត្ន*** : វាត្រូវការការយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការជ្រើសរើសឱសថដែលជួយក្មេងម្នាក់ៗអោយបានច្រើនបំផុត ហើយដែលបង្កគ្រោះថ្នាក់តិចបំផុតដល់ក្មេង។ ព្យាយាមកុំប្រើថ្នាំដែលធ្វើអោយក្មេងងងុយដេក វិលមុខ ធ្វើចលនាយឺត ឬបាត់បង់ចំណាប់អារម្មណ៍លើវត្ថុនានាច្រើនពេក។ ការប្រកាច់ ២ ឬ ៣ ដង ប្រសើរជាងការប្រើប្រាស់ថ្នាំច្រើនពេក —ដែលអាចបំពុលក្មេង។

## ការជ្រើសរើសឱសថ

ឱសថល្អបំផុតសំរាប់ក្មេងដែលមានជំងឺឆ្កួតជ្រូក គឺជាឱសថដែល :

- មានប្រសិទ្ធិភាព( បង្ការការប្រកាច់)
- មានសុវត្ថិភាព( មានផលប៉ះពាល់តិចតួច)
- មានតំលៃថោក( ពីព្រោះវាត្រូវការលេបរយៈពេលរាប់ឆ្នាំ)
- ងាយលេប( មានប្រសិទ្ធភាពយូរ ពីរបីដងក្នុងមួយថ្ងៃ)
- ងាយរកទិញ

***បំរាម*** :នៅពេលដែលក្មេងកំពុងប្រកាច់**កុំដាក់ជើងវាទៅក្នុងភ្លើង**។ វានឹងមិន"បំភ័យអោយក្មេងឱ្យត្រឡប់មករស់រវើក" វិញទេ ប៉ុន្តែវានឹងធ្វើអោយរលាកជើងក្មេងយ៉ាងធ្ងន់ធ្ងរទៅវិញ។



ឱសថច្រើនប្រភេទផ្សេងៗគ្នាត្រូវបានគេប្រើសំរាប់ជំងឺប្រគ្រីវ។ ប្រភេទខ្លះនៃការប្រកាច់អាចគ្រប់គ្រងបានដោយឱសថមួយប្រភេទ ហើយប្រភេទខ្លះទៀតត្រូវការឱសថមួយប្រភេទផ្សេងទៀត ឬដោយឱសថចំរុះ។ ការប្រកាច់របស់ក្មេងខ្លះងាយនឹងគ្រប់គ្រង។ ការប្រកាច់ខ្លះទៀតពិបាកគ្រប់គ្រង។ ចាំបាច់ត្រូវប្រើឱសថប្រភេទផ្សេងៗគ្នា និងចំរុះដើម្បីស្វែងរកការព្យាបាលដែលមានប្រសិទ្ធិភាពបំផុត។ ចំពោះក្មេងខ្លះ គ្មានឱសថណាមួយអាចគ្រប់គ្រងការប្រកាច់បានទាំងស្រុងនោះទេ។

**ឱសថដែលគួរសាកប្រើមុនគេ សំរាប់ស្ទើរតែគ្រប់ប្រភេទទាំងអស់នៃការប្រកាច់គឺ ហ្វេណូបាបីតាល់( phenobarbital)**។ ជារឿយៗ វាមានប្រសិទ្ធិភាពណាស់ ហើយវាមានសុវត្ថិភាព តំលៃថោក និងងាយលេបសមល្មម។ វាមានប្រសិទ្ធិភាពរយៈពេល ២៤ ម៉ោង ដូច្នេះលេបតែម្តងក្នុងមួយថ្ងៃគឺគ្រប់គ្រាន់។

**ប្រភេទឱសថជាបន្តសំរាប់ការប្រកាច់ខ្លាំង គឺ ហ្វេនីស៊ូរ៉ុង(phenytoin)**។ វាក៏មានសុវត្ថិភាព តំលៃថោកល្មម និងត្រូវការលេបតែម្តងប៉ុណ្ណោះក្នុងមួយថ្ងៃ។ (ប៉ុន្តែសំរាប់ជំងឺឆ្កួតជ្រូកប្រភេទខ្លះទៀតប្រើថ្នាំ **ហ្វេនីស៊ូរ៉ុង** អាចធ្វើអោយការប្រកាច់កាន់តែធ្ងន់ធ្ងរ)។

**ចំពោះជំងឺឆ្កួតជ្រូកភាគច្រើនប្រើថ្នាំ phenobarbital និង phenytoin គឺជាឱសថល្អបំផុត**។ ដំបូងសាកល្បងប្រើម្តងមួយមុខ ហើយប្រសិនបើគ្មានប្រសិទ្ធិភាព សាកល្បងប្រើទាំងពីរមុខ។ ឱសថផ្សេងទៀត ភាគច្រើនមានប្រសិទ្ធិភាពតិចជាង មានសុវត្ថិភាពតិចជាង និងមានតំលៃថ្លៃជាង។ នៅប្រទេសមួយចំនួន **ហ្វេណូបាបីតាល(phenobarbital)** ពិបាកនិងរក —ជាពិសេសប្រភេទជាថ្នាំគ្រាប់។ ជាលទ្ធផលការប្រកាច់របស់ក្មេងជាច្រើន មិនអាចគ្រប់គ្រងបានល្អ មានការប្រើឱសថដែលមានផលប៉ះពាល់ខ្លាំង និងមានតំលៃថ្លៃ។ ***បុគ្គលិកស្តារលទ្ធភាពពលកម្ម*** ត្រូវយល់ដឹងពីបញ្ហានេះ និងត្រូវធ្វើអ្វីដែលពួកគេអាចធ្វើបាន ដើម្បី**ជួយផ្តល់ឱសថដែលមានសុវត្ថិភាពបំផុត និងមានតំលៃទាបបំផុត ដែលនឹងអាចគ្រប់គ្រងការប្រកាច់របស់ក្មេងយ៉ាងមានប្រសិទ្ធិភាព**។

***ប្រយ័ត្ន*** : ដើម្បីបង្ការការឈ្លក់ ចូរកុំអោយក្មេងលេបថ្នាំពេលដែលវាកំពុងដេកផ្ងារ ឬប្រសិនបើក្បាលរបស់វាបត់ទៅក្រោយ។ ត្រូវដាក់ក្បាលវាងើបឡើងមកមុខ។ មិនត្រូវយកមាត់បញ្ចុកថ្នាំក្មេង នៅពេលដែលវាកំពុងប្រកាច់ ឬនៅពេលដែលវាកំពុងដេកលក់ ឬមិនដឹងខ្លួននោះទេ។

វាជាការប្រសើរបំផុត ក្នុង**ការចាប់ផ្តើមជាមួយនឹងឱសថប្រឆាំងការប្រកាច់តែមួយប្រភេទ — ជាធម្មតា phenobarbital** ប្រសិនបើមាន។ ចាប់ផ្តើមជាមួយនឹងកំរិតប្រើប្រាស់ពីទាបទៅមធ្យម **ហើយបន្ទាប់ពីមួយសប្តាហ៍ ប្រសិនបើការប្រកាច់មិនអាចគ្រប់គ្រងបាន និងប្រសិនបើគ្មានផលប៉ះពាល់នោះទេ ចូរបង្កើនកំរិតប្រើប្រាស់អោយខ្ពស់ជាងមុន**។ បន្ទាប់ពីរយៈពេលពីរបីថ្ងៃហើយ ថ្នាំប្រភេទទី១ នៅតែមិនអាចគ្រប់គ្រងការប្រកាច់បានទៀត ចូរប្រើថ្នាំប្រភេទទី២ —ជាធម្មតាគឺ phenytoin សំរាប់ "ការប្រកាច់ខ្លាំង"។ ដូចគ្នាដែរ ចាប់ផ្តើមជាមួយនឹងកំរិតប្រើប្រាស់ទាប ហើយបង្កើនបន្តិចម្តងៗតាមតំរូវការ។

> ***ប្រយ័ត្ន*** : នៅពេលដែលអ្នកឈប់ប្រើ ឬប្តូរថ្នាំរបស់ក្មេង ចូរធ្វើបន្តិចម្តងៗ។ ការឈប់ប្រើ ឬប្តូរថ្នាំភ្លាមៗអាចធ្វើអោយការប្រកាច់កាន់តែខ្លាំង។ ហើយវាត្រូវការរយៈពេលពីរទៅបីថ្ងៃដើម្បីអោយថ្នាំថ្មីមានប្រសិទ្ធិភាពពេញបរិបូរ។



***បំរាម*** : **គ្រប់ថ្នាំប្រឆាំងនឹងការប្រកាច់សុទ្ធតែអាចពុល ប្រសិនបើក្មេងលេបច្រើនពេក។ ត្រូវប្រយ័ត្នប្រយែងផ្តល់កំរិតប្រើប្រាស់អោយត្រឹមត្រូវ និងរក្សាទុកអោយឆ្ងាយពីក្មេង។**

## ពត៌មានស្តីពីកំរិតប្រើប្រាស់ និងការប្រុងប្រយ័ត្នជាមុន សំរាប់ថ្នាំប្រឆាំងការប្រកាច់

**ហ្វេណូបាបីតាល(Phenobarbital) (phenobarbitone, *Luminal*)**

ចំពោះការប្រកាច់គ្រប់ប្រភេទ អាចប្រើប្រាស់ដូចនេះ :

ថ្នាំគ្រាប់ ១៥មីល្លីក្រាម
ថ្នាំគ្រាប់ ៣០មីល្លីក្រាម (វាចំណាយតិចជាងក្នុងការទិញថ្នាំគ្រាប់
ថ្នាំគ្រាប់ ១០០មីល្លីក្រាម ១០០មីល្លីក្រាម រួចកាត់វាជាបំណែក។)

***កំរិតប្រើប្រាស់ :*** ដោយសារទំហំនៃគ្រាប់ថ្នាំខុសៗគ្នា យើងនឹងផ្តល់កំរិតប្រើប្រាស់ជាមីល្លីក្រាម(ម.ក.)

ការប្រើប្រាស់ជាធម្មតា គឺ ៣ ទៅ ៦ ម.ក. សំរាប់ទម្ងន់ខ្លួនមនុស្សចំនួនមួយគីឡូក្រាម ជារៀងរាល់ថ្ងៃ (៣ ទៅ ៦ ម.ក./គ.ក./ថ្ងៃ)
- ជាធម្មតា **២ដង** (ព្រឹក និងល្ងាច):

ផ្តល់របប ២ដង ក្នុងមួយថ្ងៃ។ របបនិមួយៗមានដូចខាងក្រោម :

ក្មេងអាយុលើស ១២ឆ្នាំ ............................................................... ៥០ ទៅ ១៥០ ម.ក.
ក្មេងអាយុពី ៧ ទៅ ១២ឆ្នាំ............................................................ ២៥ ទៅ ៥០ ម.ក.
ក្មេងអាយុតិចជាង ៧ ឆ្នាំ.............................................................. ១០ ទៅ ២៥ ម.ក.

**ផលប៉ះពាល់**

- ច្រើនពេកអាចបណ្តាលអោយក្មេងងងុយដេក ឬដកដង្ហើមយឺត។
- ក្មេងដែលរពិស នឹងរពិសហួសហេតុ ឬមានឥរិយាបថមិនល្អ។
- ផលប៉ះពាល់មិនសូវកើតឡើង ដូចជាការវិលមុខបន្តិចបន្តួច ការញ្ញាក់ភ្នែក និងការរមាស់ស្បែក។
- អាចមានបញ្ហានៃការលូតលាស់ឆ្អឹង —ជាពិសេសចំពោះក្មេងដែលមានប្រាជ្ញាលូតលាស់យឺត។ ការផ្តល់វីតាមីន D បន្ថែមអាចជួយបាន។
- ល្វីង។ អាចកិនថ្នាំអោយគេលេបដោយលាយជាមួយនិងទឹកឃ្មុំ ឬដំណាប់។
- បង្កើតជាទម្លាប់តូចតាច។

***ប្រុងប្រយ័ត្ន :*** ប្រសិនបើប្រើថ្នាំគ្រាប់ ១០០ ម.ក. ក្រុមគ្រួសារត្រូវយល់ដឹង ហើយកាត់វាជាបំណែក។ ធ្វើបង្ហាញពួកគេជាមុន ហើយអោយគេធ្វើសាកល្បង។



**ការអោយក្មេងលេបថ្នាំទាំងមូល មិនមែនមួយចំរៀកអាចបំពុលក្មេង។**

**ហ្វេនីស៊ីន** (**Phenytoin**) (**diphenylhydantoin,** ***Dilantin***)

ចំពោះការប្រកាច់គ្រប់ប្រភេទ លើកលែងតែការប្រកាច់មួយភ្លែត ដែលភ្លាមធ្វើអោយក្មេងបាត់ជំហរ(ការប្រកាច់កន្ត្រាក់) ឬ"ការប្រកាច់បន្តិចបន្តួច" ដោយមានការសំលឹង ព្រិចភ្នែក ឬការធ្វើចលនាលឿននៃភ្នែក។ (ហ្វេនីស៊ីន អាចធ្វើអោយការប្រកាច់នេះកាន់តែធ្ងន់ធ្ងរ)។

ជាទូទៅមាន : ថ្នាំគ្រាប់ ៣០ ម.ក.
ថ្នាំគ្រាប់ ១០០ ម.ក.
ថ្នាំទឹក ១២៥ ម.ក. ដែលមានចំណុះ ៥ ម.ល. (មួយស្លាបព្រាកាហ្វេ)



***កំរិតការប្រើប្រាស់ :*** ប្រើថ្នាំគ្រាប់ ១០០ ម.ក. ពី ៥ ទៅ ១០ ម.ក./គ.ក./ថ្ងៃ

ចាប់ផ្តើមជាមួយនិងកំរិតប្រើប្រាស់ដូចខាងក្រោមក្នុងមួយថ្ងៃ :
ក្មេងអាយុលើស ១២ឆ្នាំ ....................១០០ ទៅ ៣០០ ម.ក. ( ១ ទៅ ៣គ្រាប់)
ក្មេងអាយុពី ៧ ទៅ ១២ឆ្នាំ...............................១០០ ម.ក. (១គ្រាប់)
ក្មេងអាយុ ៦ ឬតិចជាង ៦ឆ្នាំ.................................៥០ ម.ក. (១/២ គ្រាប់)

បន្ទាប់ពីរយៈពេល២សប្តាហ៍ ប្រសិនបើការប្រកាច់មិនអាចបង្ការបានទាំងស្រុងទេ អាចបង្កើនកំរិតប្រើប្រាស់ ប៉ុន្តែមិនត្រូវលើសពីរដងនៃបរិមាណដើមនោះទេ។

ប្រសិនបើក្មេងមិនប្រកាច់រយៈពេលជាច្រើនសប្តាហ៍ ព្យាយាមបន្ថយកំរិតប្រើប្រាស់បន្តិចម្តងៗ រហូតអ្នកអាចរកឃើញកំរិតដែលទាបបំផុតដែលអាចបង្ការការប្រកាច់បាន។

## ផលប៉ះពាល់ និងបញ្ហា

***ប្រយ័ត្ន*** : ចូរពិនិត្យរកមើល**ការវិលមុខ ការញ្ញាក់ភ្នែក ការមើលបែករូបជាពីរ** និង**ការងងុយដេកខ្លាំង**។ បន្ថយកំរិតនៃការប្រើប្រាស់ បើបញ្ហាទាំងនេះកើតឡើង។ ពួកវាជាសញ្ញាដំបូងនៃការពុល ដែលអាចបង្កការខូចខួរក្បាលជាអចិន្ត្រៃយ៍។

- **ការហើម និងការដុះមិនប្រក្រតីនៃអញ្ចាញធ្មេញ** ច្រើនកើតឡើងចំពោះការប្រើប្រាស់យូរ។ វាអាចបង្ការដោយការថែទាំសុខភាពមាត់ធ្មេញ។**ត្រូវអោយក្មេងដុសសំអាតមាត់ និងធ្មេញបន្ទាប់ពីញុំអាហាររួច។** ប្រសិនបើវាមិនអាចធ្វើដោយខ្លួនឯងទេ ចូរជួយវាឬកាន់តែប្រសើរបើបង្រៀនវា។ ប្រសិនបើបញ្ហាអញ្ចាញធ្មេញធ្ងន់ធ្ងរ ចូរពិចារណាផ្លាស់ប្តូរថ្នាំ។ (សូមអាន*នៅកន្លែង ដែលគ្មានទន្តពេទ្យ*)។



អញ្ចាញធ្មេញហើមខ្លាំងស្ទើរតែលុបធ្មេញ ដែលបណ្តាលមកពី មិនបានសំអាតធ្មេញ

- ការប៉ះពាល់ម្តងម្កាល : សក់ក្បាលកើនឡើង រមាស់ មិនឃ្លានចំណី ក្អួត។
- កំរិតប្រើប្រាស់ខ្ពស់ អាចធ្វើអោយខូចថ្លើម។
- មានបញ្ហាលូតលាស់ឆ្អឹងពេលខ្លះ — ជាពិសេសចំពោះក្មេងមានប្រាជ្ញាលូតលាស់យឺត។ ការផ្តល់វីតាមីន D បន្ថែមអាចជួយបាន។

***ប្រយ័ត្ន*** : ការឈប់ប្រើ ហ្វេនីស៊ីនភ្លាមៗអាចបណ្តាលអោយក្មេង**ប្រកាច់យូរ**។ ដូច្នេះនៅពេលឈប់ប្រើ ឬប្តូរថ្នាំ**ចូរបន្ថយកំរិតប្រើប្រាស់ បន្តិចម្តងៗ**

**កាបាម៉ាស៊ីពីន** (**Cabamazepine**) (***Tegretol***)

មានប្រយោជន៍ចំពោះការប្រកាច់គ្រប់ប្រភេទ វាជាជំរើសទីពីរ ឬប្រើលាយគ្នា។ ជាពិសេសវាមានប្រយោជន៍សំរាប់ "ការប្រកាច់ សាយកូម៉ូទ័រ (psychomotor)" (សូមអានទំព័រ ៦៥)។ គុណវិបត្តិគឺ តំលៃថ្លៃ។ (ជាសំណាងមិនល្អ វេជ្ជបណ្ឌិត ភាគច្រើនផ្តល់វាជាជំរើសទីមួយ នៅពេលដែល ឱសថដែលមានតំលៃថោកជាងដូចជា phenobarbital និង phenytoin អាចមានប្រសិទ្ធិភាពដូចគ្នា ឬប្រសើរជាង)។

ជាទូទៅមានជា : ថ្នាំគ្រាប់ ២០០ ម.ក.

***កំរិតប្រើប្រាស់*** : ១៤ ទៅ ២៥ ម.ក./គ.ក./ថ្ងៃ ចែកជា ២ ទៅ ៤ដង។ ចាប់ផ្តើមជាមួយនឹង ២០ ម.ក. ក្នុងមួយថ្ងៃ សំរាប់ទម្ងន់ក្មេងមួយគីឡូក្រាម។ ឧទាហរណ៍: ក្មេងទម្ងន់ ៣០ គ.ក. អាយុ១០ឆ្នាំ នឹងចាប់ផ្តើមជាមួយនឹង ៦០០ ម.ក. /មួយថ្ងៃ ហើយវាអាចលេបចំនួន ៣ដងក្នុងម្តង ២០០ ម.ក. - ឬ ៣ដងក្នុងមួយថ្ងៃ។

ប្រសើរបំផុតគឺញុំាជាមួយ**អាហារ**។

កំរិតប្រើប្រាស់នៃ កាបាម៉ាស៊ីពីន អាចតម្រូវទៅតាមក្មេងម្នាក់ៗ។ អាស្រ័យថាថ្នាំនេះអាចគ្រប់គ្រងការប្រកាច់បានប៉ុណ្ណា វាអាចបង្កើនដល់ ៣០ ម.ក./គ.ក./ថ្ងៃ (ប៉ុន្តែមិនអាចលើសពីនេះទេ) ឬអាចថយដល់ ១០ ម.ក./គ.ក./ថ្ងៃ។

**ផលប៉ះពាល់ និងបញ្ហា**

- កម្រមបង្កអន្តរាយដល់ថ្លើម ឬកាត់បន្ថយលទ្ធភាពនៃការកកឈាម។

## ឱសថផ្សេងទៀតដែលប្រើសំរាប់ជំងឺឆ្កួតជ្រូក

- **Primidone** (***Mysoline)*** សំរាប់ការប្រកាច់គ្រប់ប្រភេទ។ ចាប់ផ្តើមជាមួយនិងកំរិតប្រើប្រាស់ទាប ហើយបង្កើនជាបន្តបន្ទាប់ពី១០ ទៅ២៥ ម.ក./គ.ក./ថ្ងៃ ដោយចែកជា២ ឬ ៤ដង។ អាចបណ្តាលអោយងងុយគេង វិលមុខ ក្អួត ឬរមាស់។
- **Ethosuximide** ***(Zarontin)*** ជាជំរើសទីមួយសំរាប់"ការប្រកាច់បន្តិចបន្តួច "ដោយមានការសំលឹងឥតដឹងខ្លួន ការព្រិចភ្នែក និងអាចធ្វើចលនាមិនប្រក្រតី —ជាពិសេសប្រសិនបើការប្រកាច់កើតឡើងជាក្រុមនៅពេលព្រឹក និងពេលល្ងាច។ ចូរអោយ១០ ទៅ ២៥ ម.ក./គ.ក./ថ្ងៃ ចែកជា១ ឬ ២ដង ជាមួយនឹងអាហារ ដើម្បីចៀសវាងការឈឺក្រពះ។ វាអាចធ្វើអោយខូចថ្លើម តែនេះជាករណីកម្រ។
- **Valproic acid** ***(Depakene)*** ប្រើតែឯង ឬជាមួយនឹងថ្នាំប្រឆាំងការប្រកាច់ផ្សេងទៀត សំរាប់"ការប្រកាច់បន្តិចបន្តួច" ដោយមានការសំលឹងឥតដឹងខ្លួន ឬភ្លឹក ជាពិសេសនៅពេលដែលការប្រកាច់កើតឡើងជាក្រុម។ ចាប់ផ្តើមជាមួយនឹង ៥ ម.ក./គ.ក./ថ្ងៃ ហើយបង្កើនជាបន្តបន្ទាប់ដល់ ៣០ ម.ក./គ.ក./ថ្ងៃ ប៉ុន្តែមិនត្រូវអោយច្រើនជាង ៦០ ម.ក./គ.ក./ថ្ងៃទេ។ មានផលប៉ះពាល់តិចតួច។ វាអាចធ្វើអោយខូចថ្លើម តែនេះជាករណីកម្រ។
- **Mephenytoin** ***(Mesantoin)*** ប្រើដូចគ្នានឹង phenytoin ប៉ុន្តែមានគ្រោះថ្នាក់ច្រើនជាង។ អាចបញ្ឈប់រាងកាយ ក្នុងការផលិតកោសិកាឈាមស និងឈាមក្រហម។ ត្រូវការពិនិត្យឈាមជាប្រចាំ។ ៤ទៅ ១៥ម.ក./គ.ក./ថ្ងៃ ដោយចែកជា ២ដង។ (យើងលើកវាមកប្រាប់ ដើម្បីបង្អាក់ការប្រើប្រាស់វាប៉ុណ្ណោះ)។
- **Corticosteroids** ***(ឬ corticotropin)*** ថ្នាំពេលខ្លះត្រូវបានសាកល្បងប្រើសំរាប់ "ការរឹងតាំងរបស់ទារក" និង "ការប្រកាច់កន្ត្រាក់"(សូមអានទំព័រទី ៦៤) ដែលមិនអាចគ្រប់គ្រងបានដោយប្រើឱសថផ្សេងទៀត។ ប៉ុន្តែការប្រើប្រាស់ ឱសថនេះយូរ **តែងតែបង្កផលប៉ះពាល់ធ្ងន់ធ្ងរ និងអាចមានគ្រោះថ្នាក់**។ ឱសថនេះគួរតែប្រើដោយមានការណែនាំពីអ្នកមានជំនាញខ្ពស់ និងពេលដែលឱសថដទៃទៀតគ្មានប្រសិទ្ធិភាព។
- **Diazepam** ***(Valium)*** ជួនកាលប្រើសំរាប់"ការប្រកាច់របស់ទារកទើបនឹងកើត" ឬ "ការរឹងតាំងរបស់ទារក"(សូមអានទំព័រ៦៤) ប៉ុន្តែគួរសាកល្បងឱសថផ្សេងទៀតជាមុនសិន។ អាចបណ្តាលអោយងងុយដេក ឬវិលមុខ។ បង្កើតទម្លាប់តូចតាច។ ចូរអោយប្រើប្រហែល 0.2 ម.ក. សំរាប់ ១ គ.ក. នៃទម្ងន់ខ្លួនក្នុងមួយថ្ងៃ ដោយចែកជាចំនួនដង។

| |
|---|
| ***ប្រុងប្រយ័ត្នពេលមានផ្ទៃពោះ*** : ឱសថប្រឆាំងការប្រកាច់ជាច្រើន ជាពិសេស phenytoin **អាចបង្កើនគ្រោះថ្នាក់ដល់ការខូចខាតពីកំណើតនៅពេលដែលប្រើប្រាស់ដោយស្ត្រីមានផ្ទៃពោះ**។ ថ្នាំមួយចំនួនក៏ចូលទៅក្នុងទឹកដោះ។ ដូច្នេះ ស្ត្រីមានផ្ទៃពោះគួរប្រើថ្នាំនេះនៅពេលដែលមានការប្រកាច់ ឬមានសភាពធ្ងន់ធ្ងរបើមិនប្រើវា។ ស្ត្រីដែលប្រើថ្នាំប្រកាច់ មិនគួរបំបៅកូនដោយទឹកដោះទេ ប្រសិនបើគេអាចផ្តល់អាហារដល់កូនដោយមិនប្រើទឹកដោះ។ Phenobarbital ប្រហែលជាថ្នាំដែលមានសុវត្ថិភាពបំផុតពេលកំពុងមានផ្ទៃពោះ។ |

## ការព្យាបាលសំរាប់ការប្រកាច់យូរ

ពេលដែលការប្រកាច់យូរជាង ១៥ នាទី :

- ប្រសិនបើមានអ្នកដែលដឹងរបៀប ចូរចាក់ថ្នាំ IV diazepam *(Valium)* ឬ phenobarbital ចូលតាមសរសៃឈាម។

| | |
|---|---|
| <br><br>ថ្នាំអាចចាក់បាន ដ្យាស៊ីប៉ាំ( diazepam ) :<br>មនុស្សចាស់......................៥-១០ ម.ក<br>ក្មេងអាយុ៧-១២ឆ្នាំ..........៣-៥ ម.ក<br>ក្មេងក្រោម ៧ឆ្នាំ...............១ ម.ក សំរាប់ទំងន់ខ្លួន៥គ.ក | <br><br>អាចចាក់ថ្នាំ phenobarbital<br>មនុស្សចាស់.....................២០០ ម.ក<br>ក្មេងអាយុ៧-១២ឆ្នាំ..........១៥០ ម.ក<br>ក្មេងអាយុ ២-៦ឆ្នាំ...........១០០ ម.ក<br>ក្មេងក្រោម ២ឆ្នាំ...............៥០ ម.ក |

- ឬប្រើ diazepam paraldehyde ឬ Phenobarbital ប្រភេទ "ថ្នាំសុល" តាមរន្ធគូទ។

***កំណត់សំគាល់:*** ថ្នាំនេះមិនមានប្រសិទ្ធិភាពលឿនដូចគ្នានឹងការចាក់ចូលសាច់ដុំនោះទេ។ ប្រសិនបើអ្នកមានតែថ្នាំដែលចាក់បាន ឬថ្នាំទឹកចាក់វាចូលរន្ធគូទដោយប្រើ សឺរ៉ាំងដែលគ្មានម្ជុល។ ឬកិនគ្រាប់ថ្នាំ diazepam ឬ phenobarbital លាយជាមួយទឹកហើយចាក់វាចូលតាមរន្ធគូទ។



ចាក់ថ្នាំ យ៉ាស៊ីប៉ាំ ចូលពោះវៀនធំ លឿនជាងចាក់ចូលសាច់ដុំ

ប្រសិនបើការប្រកាច់មិនឈប់ក្នុងរយៈពេល ១៥នាទី បន្ទាប់ពីការប្រើថ្នាំ ដាក់ថ្នាំចំនួនដដែលម្តងទៀត។ **មិនត្រូវដាក់ថែមលើសពីម្តងនោះទេ**។

# ប្រភេទនៃការប្រកាច់ឆ្កួតជ្រូក

***កំណត់សំគាល់ :*** ពតិមាននេះ គឺសំរាប់បុគ្គលិកស្តារលទ្ធភាពពលកម្ម និងឪពុកម្តាយ ពីព្រោះវេជ្ជបណ្ឌិត និងបុគ្គលិកសុខភាពជាច្រើនព្យាបាលការប្រកាច់មិនបានត្រឹមត្រូវនោះទេ។ ដោយមានការប្រុងប្រយ័ត្នអ្នកអាចធ្វើបានល្អជាង។ ប៉ុន្តែ ការវិភាគជំងឺ និងការព្យាបាលអោយបានត្រឹមត្រូវអាចពិបាកខ្លាំងណាស់។ ប្រសិនបើអាច ចូរសុំការណែនាំពីបុគ្គលិកសុខភាពដែលបានទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់។ សុំអោយពួកគេជួយក្នុងការប្រើតារាងនេះ។ វាត្រូវបានដកស្រង់ចេញពី ***ការវិភាគ និងព្យាបាលជំងឺកុមារបច្ចុប្បន្ន*** ដោយលោក **កែម ស៊ីលវឺ** និង**អូប្រៀន** (សៀវភៅផ្សាយអំពីថ្នាំពេទ្យ) ដែលមានផ្តល់ព័ត៌មានលំអិតជាងនេះ។

| **ប្រភេទ** | **អាយុពេលចាប់ផ្តើមប្រកាច់** | **រូបរាង** | **ការព្យាបាល** |
|---|---|---|---|
| ការប្រកាច់របស់ទារកទើបនឹងកើត<br> | ពីពេលកើត ដល់ ២សប្តាហ៍ | ជារឿយមិនដូចធម្មតាបន្ទាប់ពីប្រកាច់រួច។ អាចបង្ហាញការទន់ ឬរឹងតាំងអវយវៈភ្លាមៗ មិនដកដង្ហើមរយៈពេលខ្លី យំខុសប្រក្រតីភ្នែកឡើងស្លី ព្រិចឬញាក់ភ្នែក ជញ្ជក់ឬទំពាញាក់ ឬចលនាមិនប្រក្រតីនៃរាងកាយ។<br>***ប្រយ័ត្ន :*** ត្រូវដឹងអោយប្រាកដថាការរឹងតាំងនេះមិនមែនមកពីជំងឺតេតានុស ឬរលាកស្រោមខួរ(សូមអានទំព័រ ៩៧) ។ ជំងឺឆ្កួតជ្រូកនៃទារកទើបនឹងកើត ធ្វើអោយទារកទន់។ ការរឹងតាំងនិង/ឬចលនាដែលមិនអាចគ្រប់គ្រងបាន ជាធម្មតាកើតឡើង ច្រើនខែក្រោយមក ប៉ុន្តែទារកមិនបាត់បង់ស្មារតីទេ។ | ថ្នាំ phenobarbital ឬ phenytoin ។ បន្ថែម diazepam ប្រសិនបើនៅតែមិនអាចបញ្ឈប់បាន។<br>(ការប្រកាច់ដោយសារការខូចខួរក្បាលពីកំណើត ពិបាកបញ្ឈប់ណាស់) |
| ការរឹងតាំងរបស់ទារក<br>(រោគសញ្ញារបស់វេស: West) | ៣-១៨ខែ(ពេលខ្លះរហូតដល់ ៤ឆ្នាំ)<br> | ការបើកដៃនិងជើងភ្លាមៗ ហើយបន្ទាប់មកបត់អវយវៈទាំងនោះ —ឬធ្វើចលនាមិនប្រក្រតីដដែលៗ។ ការរឹងតាំងជារឿយៗកើតឡើងដដែលៗជាក្រុម នៅពេលដើរ ឬដាក់ខ្លួនដេក ឬនៅពេលហត់ខ្លាំងឈឺ ឬមិនសប្បាយចិត្ត។<br>ក្មេងភាគច្រើនដែលមានបញ្ហានេះ មានប្រាជ្ញាល្ងូតលាស់យឺត។ | អាចសាកប្រើថ្នាំ corticosteroids — ប៉ុន្តែវាមានគ្រោះថ្នាក់។ ព្យាយាមរកជំនួយពីវេជ្ជបណ្ឌិត ឬបុគ្គលិកសុខភាពដែលមានបទពិសោធន៍។ Valproic acid និង diazepam អាចជួយបាន។ |
| ការប្រកាច់ដោយសារគ្រុន (ការប្រកាច់ដែលកើតឡើងពេលក្មេងគ្រុន)<br> | ៦ខែ ទៅ ៤ឆ្នាំ | ជាធម្មតាប្រកាច់ខ្លាំង (សូមអានទំព័របន្ទាប់) ដែលកើតឡើងនៅពេលដែលក្មេងគ្រុនដោយសារបុព្វហេតុផ្សេងទៀត (ឈឺករោគឆ្លងក្នុងត្រចៀក ផ្តាសាយធំ)។ អាចមានរយៈពេល ១៥នាទី ឬយូរជាងនេះ។ ជារឿយៗមានប្រវត្តិប្រកាច់ដោយសារគ្រុននៅក្នុងក្រុមគ្រួសារ។<br>***ប្រយ័ត្ន :*** ចូររកសញ្ញានៃរោគរលាកស្រោមខួរ។ | ក្មេងដែលប្រកាច់ដោយសារគ្រុនជាច្រើនដង គួរតែព្យាបាលដោយថ្នាំ phenobarbital ជាបន្តបន្ទាប់រហូតដល់អាយុ ៤ឆ្នាំ ឬមួយឆ្នាំក្រោយពីការប្រកាច់ចុងក្រោយ។ ជាធម្មតាការប្រកាច់មិនបន្តមកក្នុងវ័យក្រោយមកទៀតរបស់ក្មេងទេ។ |
| ការប្រកាច់កន្ត្រាក់ ឬ "រន្ទះផ្គរ" (រោគសញ្ញា Lennox Gastaut)<br> | នៅគ្រប់វ័យ ប៉ុន្តែជាពិសេសនៅអាយុ ៤-៧ ឆ្នាំ | ការរឹងតាំងភ្លាមៗនៃសាច់ដុំមួយចំនួនដោយគ្មានផ្តល់សញ្ញាអាសន្ន ដែលអាចអោយក្មេងបោកខ្លួនទៅចំហៀង ទៅមុខ ឬទៅក្រោយ។ ជាធម្មតា មិនបាត់បង់ស្មារតីនោះទេ ឬគ្រាន់តែភ្លឹក។ ក្មេងជាច្រើន ក៏ប្រកាច់ខ្លាំង ឬទូទៅ។ មានប្រវត្តិ"រឹងតាំងទារក"(សូមអានខាងលើ) កាលពីនៅកុមារភាព។ | សាកល្បងប្រើ phenobarbital ជាមួយនឹង valproic acid ។ ប្រសិនបើគ្មានប្រសិទ្ធិភាព សាកល្បងប្រើ corticosteroids ដូចករណីរឹងតាំងរបស់ទារកឬថ្នាំផ្សេងទៀតដែលមានការណែនាំពីពេទ្យ។ ការពារក្បាលក្មេងជាមួយនិងមួកការពារ និងទ្រនាប់ចង្កា។<br> |

| ប្រភេទ | អាយុពេលចាប់ផ្តើមប្រកាច់ | រូបរាង | ការព្យាបាល |
|---|---|---|---|
| ការភ្លឹក (petit mal) (ការប្រកាច់បែបនេះតែឯង គឺជាករណីកម្រ) | ៣-១៥ ឆ្នាំ  | ក្មេងបញ្ឈប់អ្វីដែលវាកំពុងធ្វើភ្លាមៗ ហើយមានរូបរាងមិនប្រក្រតី លក្ខណៈភ្លឹកមួយសន្ទុះ ។ ជាធម្មតា វាមិនដួលទេ ប៉ុន្តែហាក់ដូចជាមើលមិនឃើញ ឬស្តាប់មិនឮនៅពេលប្រកាច់ ។ ការភ្លឹកនេះ ធម្មតាកើតឡើងជាក្រុម ។ វាអាចធ្វើចលនាដោយមិនដឹងខ្លួន ឬភ្នែកវាធ្វើចលនាលឿន ឬព្រិច ។ ការប្រកាច់នេះអាចជួយអោយប្រសើរបានតាមរយៈការដកដង្ហើមលឿន និងវែងៗ ។ (ប្រើជាការសាកល្បង ។) ជារឿយៗអាចច្រលំគ្នានឹង ការប្រកាច់psychomotor ដែលកើតឡើងច្រើនជាង ។ | ប្រើ valproic acid ឬ ethosuximinde ។ ដោយហេតុថាក្មេងជាច្រើន ប្រកាច់ខ្លាំង ចូរបន្ថែម phenobarbital ប្រសិនបើចាំបាច់ (ឬសាកប្រើវាមុន បើអ្នកយល់ថាវាអាចជាការប្រកាច់ psychomotor — សូមអានខាងក្រោម) ។ |
| ការប្រកាច់រាលដាល (ការប្រកាច់ប្រសព្វគ្នា) | គ្រប់វ័យ | ចលនាចាប់ផ្តើមនៅផ្នែកណាមួយនៃរាងកាយ ។ អាចរាលដាលក្នុងសណ្ឋានជាក់លាក់ណាមួយ (ការរាលដាល Jacksonian) ហើយក៏ប្រកាច់គ្រប់កន្លែង ។  ***កំណត់សំគាល់ :*** ប្រសិនបើការប្រកាច់នៃផ្នែកណាមួយនៃរាងកាយមានសភាពកាន់តែខ្លាំងឡើងៗ ឬសញ្ញាខូចខួរក្បាលផ្សេងៗលេចឡើង បុព្វហេតុអាចជាសាច់ដុះក្នុងខួរក្បាល ។ | ប្រើ phenobarbital ឬ phenytoin (ឬទាំងពីរ) ។ ប្រសិនមានលទ្ធផលមិនល្អ សាកប្រើ carbazepine ឬ carbarmazepine ឬ primidone ។ |
| ការប្រកាច់រាងកាយ និងចិត្តគំនិត(psychomotor)  | គ្រប់វ័យ | ចាប់ផ្តើម "សញ្ញាអាសន្ន" : អារម្មណ៍ភ័យខ្លាច បញ្ហាក្រពះ ក្លិន ឬរស់ជាតិចម្លែក ស្រមៃឮ ឬឃើញវត្ថុនានា ។ ការប្រកាច់អាចមានការសំលឹងភ្លឹក ចលនាមិនប្រក្រតីនៃមុខ អណ្តាត ឬមាត់ សំលេងចំលែក ឬចលនាប្លែកៗដូចជាទាញសំលៀកបំពាក់ ។ មិនដូចគ្នានឹង "ការភ្លឹក" នោះទេ ការប្រកាច់នេះជាធម្មតាមិនកើតឡើងជាក្រុមទេ វាកើតឡើងតែឯង ហើយមានរយៈពេលយូរជាង ។ ក្មេងភាគច្រើនដែលប្រកាច់បែបនេះ នឹងប្រកាច់ខ្លាំងនៅពេលក្រោយ ។ | សាកល្បងប្រើ phenobarbital មុនសិន — បន្ទាប់មក phenytoin ឬទាំងពីរព្រមគ្នា បន្ទាប់មក carbamazepine ឬទាំងបីរួមគ្នា ។ Valproic acid អាចមានប្រយោជន៍ផងដែរ ។ ឬប្រើ primidone ជំនួសអោយ phenobarbital ។ ជូនកាលការប្រឹក្សាផ្លូវចិត្តអាចជួយបានខ្លះដែរ ។ |
| ការប្រកាច់ទាំងអស់ ឬ "ខ្លាំង" (grand mal)  | គ្រប់វ័យ | បាត់បង់ស្មារតី — ជារឿយៗបន្ទាប់ពីមានអារម្មណ៍ប្រាប់អាសន្នព្រាលៗ ឬបន្ទាប់ពីយំ ។ ចលនារមួរ ឬខ្លាំងក្លា មិនអាចគ្រប់គ្រងបាន ។ ភ្នែកឡើងស្លី ។ អាចខាំអណ្តាត ឬ មិនអាចគ្រប់គ្រងបត់ជើងតូច និងបន្ទោបង់បាន ។ បន្ទាប់មកមានការច្របូកច្របល់ និងដេកលក់ ។ ជារឿយៗ កើតឡើងរួមផ្សំជាមួយនឹងការប្រកាច់ប្រភេទផ្សេងទៀត ។ មានប្រវត្តិប្រកាច់ក្នុងក្រុមគ្រួសារ ។ | សាកល្បងប្រើ phenobarbital មុនសិន ។ បន្ទាប់មក phenytoin ។ បន្ទាប់មក carbamazepine ឬប្រើលាយគ្នា ។ ឬប្រើprimidone ឬ methsuximide លាយជាមួយនឹងថ្នាំណាមួយក្នុងចំណោមថ្នាំខាងលើ ។ |

| | | | |
|---|---|---|---|
| ការប្រកាច់ដោយសារអារម្មណ៍មួម៉ៅខ្លាំង (មិនមែនជាជំងឺឆ្កួតជ្រូកទេ) | ក្រោម ៧ ឆ្នាំ  | ក្មេងខ្លះដែលប្រកាច់ដោយសារការខឹង ឈប់ដកដង្ហើម ហើយឡើងពណ៌ខៀវ ។ ការខ្វះខ្យល់អាចធ្វើអោយបាត់បង់ស្មារតីមួយសន្ទុះ ហើយការកន្ត្រាក់ (ការរឹងតាំងសាច់ដុំ ភ្នែកស្លី) ។ ការប្រកាច់មួយភ្លែតដែលក្មេងឡើងខៀវ**មុន**បាត់ស្មារតីនេះ គ្មានគ្រោះថ្នាក់ទេ ។ | មិនត្រូវការព្យាបាលដោយថ្នាំទេ ។ ប្រើវិធីសាស្ត្រជួយអោយក្មេងកែលំអឥរិយាបថរបស់ខ្លួន ។ |

## ជួយសហគមន៍យល់ដឹងពីជំងឺឆ្កួតជ្រូក

ការប្រកាច់អាចបំភ័យអ្នកដែលបានឃើញ។ ដោយសារហេតុផលនេះក្មេង (និងមនុស្សពេញវ័យ) ដែលមានជំងឺឆ្កួតជ្រូក ពេលខ្លះមានការពិបាកក្នុងការទទួលយកនៅក្នុងសហគមន៍។

បុគ្គលិកស្តារលទ្ធភាពពលកម្ម ត្រូវជួយអោយមនុស្សគ្រប់គ្នាក្នុងសហគមន៍យល់ដឹងថា **ជំងឺឆ្កួតជ្រូកមិនមែនជាលទ្ធផលនៃការធ្វើអំពើ** ឬជាទង្វើរបស់ព្រលឹងអាក្រក់នោះទេ។ វា**មិនមែនជាសញ្ញានៃភាពឆ្កួតមិនមែនជាកម្មផល**ដែលក្មេង ឬឪពុកម្តាយបានធ្វើ **មិនមែនជាជំងឺឆ្លង** និង**មិនអាចឆ្លងរាលដាលដល់អ្នកដទៃទេ**។

វាមានសារៈសំខាន់ដែលក្មេងមានជំងឺឆ្កួតជ្រូកទៅរៀន និងចូលរួមក្នុងការងារប្រចាំថ្ងៃ ការលេង និងដំណើរផ្សងព្រេងនៅក្នុងក្រុមគ្រួសារ និងក្នុងភូមិ។ វាជារឿងពិត ទោះបីជាមិនអាចគ្រប់គ្រងការប្រកាច់បានទាំងស្រុងក៏ដោយ។ គ្រូបង្រៀន និងក្មេងឯទៀតគួរស្វែងយល់ពីជំងឺឆ្កួតជ្រូក និងរបៀបការពារក្មេងពេលដែលវាប្រកាច់។ ប្រសិនបើពួកគេរៀនកាន់តែច្រើនពីជំងឺឆ្កួតជ្រូក វានឹងជួយអោយពួកគេចង់ជួយ ជាជាងភ័យខ្លាច។

ទោះបីជាក្មេងមានជំងឺឆ្កួតជ្រូកគួរតែទទួលបាននូវការលើកទឹកចិត្ត ក្នុងការរស់នៅក្នុងជីវិតសាមញ្ញ និងសកម្ម គេត្រូវមានការប្រុងប្រយ័ត្នជាមុនមួយចំនួនផងដែរ—ជាពិសេសចំពោះក្មេងដែលប្រកាច់ភ្លាមៗដោយគ្មានសញ្ញាអាសន្ន។ ក្មេងក្នុងភូមិ អាចរៀនជួយរក្សាសុវត្ថិភាពសំរាប់ក្មេង —ជាពិសេស នៅពេលដែលអាចមានគ្រោះថ្នាក់ខ្លាំង។




## ការបង្ការជំងឺឆ្កួតជ្រូក

១- ព្យាយាមចៀសវាងការធ្វើអោយខូចខួរក្បាល — ពេលកំពុងមានផ្ទៃពោះ ពេលកើត និងក្នុងវ័យកុមារ។ ចំណុចត្រូវបានពិភាក្សានៅក្នុងអត្ថបទស្តីពីការបង្ការជំងឺឆ្កួតជ្រូក ទំព័រទី ៣៩។

២- ចៀសវាងការរៀបការរវាងសាច់ឈាមជិតគ្នា ជាពិសេសនៅក្នុងក្រុមគ្រួសារដែលមានប្រវត្តិជំងឺឆ្កួតជ្រូក។

៣- នៅពេលដែលក្មេងមានជំងឺឆ្កួតជ្រូកប្រើថ្នាំប្រឆាំងការប្រកាច់ជាប្រចាំ ជួនកាលការប្រកាច់មិនកើតឡើងទៀតទេ ពេលដែលឈប់ប្រើថ្នាំ។ ដើម្បីកុំអោយការប្រកាច់កើតឡើងជាថ្មី ត្រូវអោយក្មេងប្រើថ្នាំប្រឆាំងការប្រកាច់អោយបានយ៉ាងតិចមួយឆ្នាំបន្ទាប់ពីការប្រកាច់ចុងក្រោយរបស់វា។ (ប៉ុន្តែជារឿយៗ ការប្រកាច់នឹងកើតឡើងវិញនៅពេលឈប់ប្រើថ្នាំ។ ប្រសិនបើបញ្ហានេះកើតឡើង គួរប្រើថ្នាំរយៈពេលយ៉ាងតិចមួយឆ្នាំទៀតមុនពេលដែលអ្នកព្យាយាមឈប់ប្រើម្តងទៀត។)